ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ អនុក្រ.បក

# សេចក្ដីសម្រេច

## ស្ដីពី

## ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣/ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំឧបង្ការសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញសេចក្ដីសំរេចលេខ ២៤៥ សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

Downloaded from http://www.khmerlaws.com

សម្រេច

ប្រការ ១.-

សេចក្តីសំរេចនេះ មានគោលដៅកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន ដែលបានកំណត់ក្នុងសេចក្តីសំរេចលេខ ២៤៥សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ។

ប្រការ ២.-

ត្រូវបានឧបត្ថម្ភជាថវិកា ដើម្បីរួមចំណែក និងជួយដល់គ្រួសារសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព សំរាប់ធ្វើពិធីបុណ្យតាមប្រពៃណី ក្នុងម្នាក់ៗ ដូចខាងក្រោម :

- ទទួលមរណភាពដោយជំងឺធម្មតា ចំនួន *១ ២០០ ០០០ រៀល ( មួយលាន ពីររយ រៀល)*
- ទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬ គ្រោះថ្នាក់ការងារ ចំនួន *១ ៥០០ ០០០ រៀល ( មួយលាន ប្រាំរយ រៀល )* ។

ប្រការ ៣.-

មន្ត្រីរាជការស៊ីវិលជាស្ត្រីភេទដែលសំរាលកូន និងសំរាកលំហែមាតុភាព ត្រូវបានទទួលថវិកាឧបត្ថម្ភក្នុងម្នាក់ចំនួន *៦០០ ០០០ រៀល ( ប្រាំមួយរយ ពាន់ រៀល)* ។

ប្រការ ៤.-

ផលប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន នឹងមានកំណត់ដោយឡែក ។

ប្រការ ៥.-

នីតិវិធី និងបែបបទនៃការអនុវត្តសេចក្តីសម្រេចនេះ នឹងកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ។

Downloaded from http://www.khmerlaws.com

ប្រការ ៧.-

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

Downloaded from http://www.khmerlaws.com